# ថ្នាំបង្ការជំងឺ COVID-19
# អ្វីដែលឪពុកម្តាយត្រូវស្វែងយល់

## ថ្នាំបង្ការទាំងឡាយការពារពីការទទួលបានលទ្ធផលដ៏មិនល្អបំផុតដោយសារជំងឺ COVID។

- បើទោះបីជាជំងឺ COVID-19 ជាទូទៅមានកម្រិតស្រាលចំពោះកុមារក៏ដោយ កុមារដែលមានសុខភាពល្អក៏អាចធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ ត្រូវចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬក៏ស្លាប់ដោយសារជំងឺ COVID-19 បានផងដែរ។ កុមារជាច្រើនក៏អាចកើតមានបញ្ហាផ្នែកសុខភាពផ្លូវចិត្ត និងផ្លូវកាយរយៈពេលវែងដោយសារការឆ្លងជំងឺ COVID-19 (ដែលហៅថាជំងឺ COVID រយៈពេលវែង) ផងដែរ។
- ថ្នាំបង្ការជំងឺ COVID-19 កាត់បន្ថយហានិភ័យនៃការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរដោយសារជំងឺ COVID-19។ ថ្នាំបង្ការក៏កាត់បន្ថយហានិភ័យនៃការកើតមានជំងឺ COVID រយៈពេលវែង ផងដែរ។
- ថ្នាំបង្ការជំងឺ COVID-19 ប្រភេទ Pfizer និងប្រភេទ Moderna ទាំងអស់គឺជាថ្នាំបង្ការដែលបានធ្វើឱ្យថ្មីឡើងវិញ (បែប ប្រឆាំងនឹងមេរោគពីរប្រភេទ/បាយវ៉ាលិន) (bivalent)។ នេះមានន័យថាថ្នាំបង្ការទាំងនេះត្រូវបានធ្វើឱ្យថ្មីឡើងវិញ ដើម្បីការពារប្រឆាំងនឹងពូជមេរោគថ្មីៗច្រើនទៀត។



**មានការណែនាំឱ្យកុមារទាំងអស់ដែលមានអាយុចាប់ពី 6 ខែឡើងទៅ ទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ដែលបានធ្វើឱ្យថ្មីឡើងវិញ (updated COVID-19 vaccine)។**



- **កុមារទាំងឡាយដែលមានអាយុចាប់ពី 6 ឆ្នាំឡើងទៅ ហើយដែល៖**
  - **បានទទួលចាក់ថ្នាំបង្ការដែលបានធ្វើឱ្យថ្មីឡើងវិញចំនួនមួយដូសរួចហើយនោះ គឺបានគ្រប់លក្ខណៈនិងទាន់ពេលវេលា។** ប្រសិនបើពួកគេមានប្រព័ន្ធភាពស៊ាំចុះខ្សោយ ពួកគេអាចនឹងទទួលចាក់ដូសបន្ថែមទៀត។
  - **មិនធ្លាប់បានទទួលចាក់ថ្នាំបង្ការណាមួយ ឬមិនធ្លាប់បានទទួលចាក់ថ្នាំបង្ការដែលបានធ្វើឱ្យថ្មីឡើងវិញទេនោះ គួរតែទទួលចាក់ថ្នាំបង្ការប្រភេទនេះចំនួនមួយដូស។**
- **កុមារទាំងឡាយដែលមានអាយុចាប់ពី 6 ខែ ទៅ 5 ឆ្នាំ** អាចនឹងត្រូវការចាក់ដូសថ្នាំបង្ការបន្ថែមទៀត ដើម្បីបានគ្រប់លក្ខណៈនិងទាន់ពេលវេលា រួមមានទាំងថ្នាំបង្ការដែលបានធ្វើឱ្យថ្មីឡើងវិញយ៉ាងហោចណាស់ចំនួនមួយដូសផងដែរ។ ចំនួនដូសថ្នាំបង្ការគឺអាស្រ័យទៅលើអាយុរបស់ពួកគេ ហើយនិងថាតើពួកគេបានទទួលចាក់ថ្នាំបង្ការប្រភេទណាមួយ (ឬច្រើនប្រភេទ) រួចហើយនោះ។ សម្រាប់ព័ត៌មានបន្ថែម សូមពិគ្រោះជាមួយនឹងគ្រូពេទ្យរបស់ពួកគេ ឬចូលទៅកាន់គេហទំព័រ cdc.gov/coronavirus/vaccine។

- កុមារទាំងឡាយដែលធ្លាប់ឆ្លងជំងឺ COVID រួចហើយនោះ ក៏គួរតែទទួលចាក់ថ្នាំបង្ការផងដែរ។
- ថ្នាំបង្ការជំងឺ COVID-19 អាចមានផ្តល់ជូនស្របពេលជាមួយគ្នានឹងពេលផ្តល់ជូនថ្នាំបង្ការជំងឺតាមទម្លាប់ពេលនៅកុមារភាពផ្សេងៗទៀតបាន ផងដែរ។

## របៀបទទួលចាក់ថ្នាំបង្ការ

- សូមចូលទៅកាន់គេហទំព័រ **ph.lacounty.gov/howtogetvaccinated** ដើម្បីស្វែងរកទីតាំងមួយដែលនៅជិតអ្នក។ សូមប្រាកដថាទីតាំងទាំងនោះមានថ្នាំបង្ការដែលត្រឹមត្រូវសម្រាប់អាយុកូនរបស់អ្នក ហើយសូមសាកសួរអំពី **ការអនុញ្ញាតពីឪពុកម្តាយ ឬអ្នកផ្តល់ការមើលថែទាំ (parent/caregiver consent)**។ ឱសថស្ថានភាគច្រើនមិនអាចផ្តល់ថ្នាំបង្ការជូនដល់កុមារដែលមានអាយុក្រោម 3 ឆ្នាំនោះទេ។
- សូមទូរស័ព្ទទៅកាន់មជ្ឈមណ្ឌលផ្តល់ព័ត៌មានអំពីថ្នាំបង្ការ របស់នាយកដ្ឋានសុខភាពសាធារណៈ (DPH Vaccine Call Center) តាមរយៈលេខ **1-833-540-0473** ឬលេខ **2-1-1** ប្រសិនបើអ្នកត្រូវការជំនួយក្នុងការស្វែងរកថ្នាំបង្ការ ឬមធ្យោបាយធ្វើដំណើរ ឬក៏ការចាក់ថ្នាំបង្ការនៅតាមផ្ទះ។
- ថ្នាំបង្ការទាំងឡាយគឺមិនគិតថ្លៃចំពោះមនុស្សគ្រប់រូប។ អ្នកមិនត្រូវការមានធានារ៉ាប់រងនោះទេ ហើយអ្នកក៏នឹងមិនត្រូវបានសាកសួរអំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នកនោះដែរ។



កំណត់សម្គាល់៖ ថ្នាំបង្ការប្រភេទ Novavax បែប ប្រឆាំងនឹងមេរោគតែមួយប្រភេទ/ម៉ូណូវ៉ាលិន (monovalent) គឺមានសម្រាប់ផ្តល់ជូនអ្នកដែលមានអាយុចាប់ពី 12 ឆ្នាំឡើងទៅ ក្នុង ស្ថានភាពមួយចំនួន។

COUNTY OF LOS ANGELES Public Health

# ថ្នាំបង្ការជំងឺ COVID-19
# អ្វីដែលឪពុកម្ដាយត្រូវស្វែងយល់



## ផលប៉ះពាល់ផ្សេងៗរបស់ថ្នាំបង្ការ

- កូនរបស់អ្នកអាចនឹងមានផលប៉ះពាល់ដែលប្រហាក់ប្រហែលគ្នាទៅនឹងផលប៉ះពាល់នៃការចាក់ថ្នាំបង្ការជំងឺតាមទម្លាប់ផ្សេងៗទៀតផងដែរ។ ជាធម្មតា ផលប៉ះពាល់ទាំងឡាយ **មានកម្រិតស្រាល ហើយនឹងបាត់ទៅវិញ** ក្នុងអំឡុងពេលប៉ុន្មានថ្ងៃក្រោយ។ កុមារមួយចំនួនមិនកើតមានផលប៉ះពាល់ទេ។
- ផលប៉ះពាល់ទូទៅរួមមានដូចជា ការឈឺ ឡើងហើម ឬឡើងក្រហមនៅនឹងដៃ ឬភ្លៅ នៅត្រង់កន្លែងដែលបានចាក់ថ្នាំបង្ការនោះ ឈឺសាច់ដុំឬឈឺតាមសន្លាក់ ហើមកូនកណ្ដុរ គ្រុនក្ដៅ គ្រុនរងា ឈឺក្បាល ឆាប់ខឹងឬឆាប់យំ មានអារម្មណ៍អស់កម្លាំង ងងុយគេង និងបាត់បង់ចំណង់អាហារ។

បរិមាណដូសនៃថ្នាំបង្ការជំងឺ COVID-19 គឺផ្អែកទៅលើអាយុរបស់កុមារ ហើយមិនមែនផ្អែកទៅលើមាឌ ឬទម្ងន់របស់ពួកគេនោះទេ។ កុមារទាំងឡាយដែលមានអាយុចាប់ពី 12 ឆ្នាំឡើងទៅ ទទួលចាក់កម្រិតដូសថ្នាំបង្ការដែលដូចគ្នាទៅនឹងដូសសម្រាប់មនុស្សពេញវ័យផងដែរ។






## សុវត្ថិភាពទាក់ទងទៅនឹងថ្នាំបង្ការ

- **ថ្នាំបង្ការជំងឺ COVID-19 ទាំងឡាយមានសុវត្ថិភាពសម្រាប់កុមារ។** មុនពេលធ្វើការណែនាំថ្នាំបង្ការជំងឺ COVID-19 សម្រាប់កុមារនោះ មានការធ្វើតេស្តសាកល្បងបែបវេជ្ជសាស្ត្រ (clinical trials) ចំពោះកុមាររាប់ពាន់នាក់ ដើម្បីស្វែងយល់អំពីសុវត្ថិភាពរបស់ថ្នាំបង្ការទាំងឡាយ និងថាតើថ្នាំបង្ការទាំងនេះដំណើរការបានល្អកម្រិតណា។ ចាប់តាំងពីពេលនោះមក កុមាររាប់សិបលាននាក់នៅក្នុងសហរដ្ឋអាមេរិកបានទទួលចាក់ថ្នាំបង្ការ។
- ថ្នាំបង្ការជំងឺ COVID-19 ទាំងឡាយបានឆ្លងកាត់ — និងនៅតែបន្តឆ្លងកាត់ — **ការត្រួតពិនិត្យផ្នែកសុវត្ថិភាពយ៉ាងយកចិត្តទុកដាក់** បំផុតក្នុងប្រវត្តិសាស្ត្រសហរដ្ឋអាមេរិក។
- មានការរាយការណ៍ថាមានករណីនៃបញ្ហា myocarditis (ការរលាកសាចដុំបេះដូង) និងបញ្ហា pericarditis (ការរលាកស្រទាប់ខាងក្រៅនៃបេះដូង) ដែលកម្រនឹងកើតមាននោះ ចំពោះកុមារបន្ទាប់ពីការចាក់ថ្នាំបង្ការជំងឺ COVID-19 រួច ដែលភាគច្រើនមានការរាយការណ៍ថាកើតមានចំពោះមនុស្សភេទប្រុសទាំងឡាយដែលមានអាយុចាប់ពី 12 ឆ្នាំឡើងទៅ។ ទោះជាយ៉ាងណាក៏ដោយ ហានិភ័យទៅដល់បេះដូងដោយសារថ្នាំបង្ការជំងឺ COVID-19 មានកម្រិតទាបជាងខ្លាំង ធៀបនឹងហានិភ័យដោយសារការឆ្លងជំងឺ COVID-19។
- កូនរបស់អ្នក **មិនអាចកើតជំងឺ COVID-19** ពីការចាក់ថ្នាំបង្ការជំងឺ COVID-19 នោះទេ។
- មិនមានភ័ស្តុតាងណាមួយដែលបង្ហាញថា ថ្នាំបង្ការជំងឺ COVID-19 ទាំងឡាយ ប៉ះពាល់ដល់ការលូតលាស់ ឬការមានបញ្ហាមិនមានកូននោះទេ។



សម្រាប់ព័ត៌មានលម្អិតបន្ថែម សូមចូលទៅកាន់គេហទំព័រ cdc.gov/coronavirus/vaccine។

VaccinateLACounty.com

County of Los Angeles Public Health